ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៣៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការដាក់មន្ត្រីរាជការអោយនៅក្រៅក្របខ័ណ្ឌដើម ក្នុងពេលទៅបំពេញការងាររៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

សហការរៀបចំដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (GIZ)-ចម្លងខ្លឹមសារទាំងស្រុងតាមច្បាប់ដើម

- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- តាមសំណើររបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៨។

# សម្រេច

**មាត្រា ១.–**

មន្ត្រីរាជការដែលត្រូវបានតែងតាំងជាប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើមរហូតដល់មានការតែងតាំងថ្មី។ ក្នុងរយៈពេលនេះសាមីខ្លួនត្រូវបានរក្សាអតីតភាពការងារសម្រាប់ការឡើងថ្នាក់ និងសោធននិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ។

**មាត្រា ២.–**

មន្ត្រីរាជការដែលត្រូវបានជ្រើសរើសជាប្រធាន អនុប្រធាន សមាជិកនៃគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត មន្ត្រីបម្រើអោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងមន្ត្រីបម្រើការអោយគណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើមរហូតចប់ភារកិច្ច។ ក្នុងរយៈពេលនេះសាមីខ្លួនត្រូវបានរក្សាអតីតភាពការងារសម្រាប់ការឡើងថ្នាក់ នឹងសោធននិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ។

**មាត្រា ៣.–**

មន្ត្រីរាជការដែលត្រូវបានជ្រើសរើសជាប្រធាន អនុប្រធាន សមាជិកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យសុំឈប់ពិសេសទៅបម្រើការងារក្រៅក្របខ័ណ្ឌដើមរហូតដល់ថ្ងៃប្រកាសលទ្ធផលបោះឆ្នោតជាស្ថាពរ។

មន្ត្រីរាជការបម្រើអោយគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវដាក់ពាក្យសុំឈប់ពិសេសទៅបម្រើការងារ ក្រៅក្របខ័ណ្ឌដើមរហូតដល់ថ្ងៃចប់ភារកិច្ច។

ក្នុងការឈប់ពិសេសនេះមន្ត្រីរាជការត្រូវបានរក្សាបៀវត្សអតីតភាពការងារសម្រាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍។

**មាត្រា ៤.–**

មន្ត្រីរាជការដែលត្រូវបានតែងតាំងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់មានសិទ្ធិទទួលការអនុញ្ញាតអោយឈប់ពីការងារ ដើម្បីបម្រើការរៀបចំការបោះឆ្នោត និងចូលបម្រើការងារនៅអង្គភាពដើមវិញក្រោយពីចប់ភារកិច្ច។

លិខិតអនុញ្ញាតអោយឈប់សម្រាករបស់ក្រសួង ស្ថាប័ន ឬអង្គភាព ត្រូវចម្លងជូនទីស្តីការគណៈរដ្ឋមន្ត្រី និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា ៥.–**

មន្ត្រីរាជការមួយ ឬពីររូប ដែលត្រូវទៅបន្តនិរន្តរ៍ភាពការងារបោះឆ្នោតនៅគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបន្តសុំការងារនៅក្រៅក្របខ័ណ្ឌដើមចាប់ពី ៦០ ថ្ងៃក្រោយការប្រកាសលទ្ធផលជាស្ថាពរ រហូតដល់ពេលរៀបចំការបោះឆ្នោតអាណត្តិក្រោយ។ ក្នុងរយៈពេលនេះ សាមីខ្លួនមានសិទ្ធិរក្សាអតីតភាពការងារសម្រាប់ឡើងថ្នាក់ និងទទួលសោធននិវត្តន៍។

**មាត្រា ៦.–**

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងមន្ត្រីរាជការដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយបានល្អចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៨

**នាយករដ្ឋមន្ត្រីទី ១** **នាយករដ្ឋមន្ត្រីទី ២**

**អ៊ឹង ហួត** **ហ៊ុន សែន**

**កន្លែងទទួល:**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី ២
- គណៈកម្មការជាតិរៀបចំការបោះឆ្នោត
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ–កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី ១ និងសម្តេចនាយករដ្ឋមន្ត្រីទី ២

ដើម្បីសូមចុះហត្ថលេខា

**សហរដ្ឋមន្ត្រី**

**ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ស្តីទី**

**សុខ អាន** **ឈាន់ តាន់**